# ៥. ការកំណត់អំពីសក្តានុពលហេតុប៉ះពាល់បរិស្ថាននិងសង្គម និងវិធានការកាត់បន្ថយ

## ៥-១ ការកំណត់ប្រភេទគំរោង

**១៩៤. ហ្គ្រីន ខិនសាល់ថិនស៊ី ហ្វឹម** បានបញ្ជូនក្រុមការងារចុះទៅធ្វើការសិក្សា និងវាយតំលៃលើហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង (IESIA) ចំនួន ០៣ក្រុម: (១)-ការពិភាក្សាជាមួយថ្នាក់ខេត្ត ស្រុក និងមន្ទីរពាក់ព័ន្ធ ដែលចុះធ្វើការពីថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១០ (២)-ក្រុមការងារសិក្សាអំពីស្ថានភាពសេដ្ឋកិច្ចសង្គម ដែលចុះធ្វើការពីថ្ងៃទី ១-២ ខែ មេសា ឆ្នាំ២០១១ និង (៣)-ក្រុមការងារហោះហើរ បានចុះធ្វើការពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១១ លើគំរោងអភិវឌ្ឍន៍ដាំដំណាំកសិ-ឧស្សាហកម្មរបស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** ដែលមានទំហំ ៨.១០០ហិកតា ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ។

**១៩៥.** ក្រុមហ៊ុនបានប្រើគោលការណ៍ណែនាំរួមរបស់ក្រសួងបរិស្ថាន ការវាយតំលៃបានសង្កត់ធ្ងន់ទៅលើបញ្ហាមួយចំនួនមាន: (១)-ធនធានរូបវន្ត (២)-ធនធានអេកូឡូស៊ី (ស្ថានភាពគំរប និងដង់ស៊ីតេព្រៃ ប្រភេទឈើ ជុល្លិព្រឹក្ស តិណជាតិ សត្វព្រៃ) (៣)-ធនធានសង្គម (៤)-ហេតុប៉ះពាល់លើសុខភាពការងារនិងផែនការសុវត្ថិភាព (៥)-ហេតុប៉ះពាល់ក្នុងតំបន់ និង (៦)-ហេតុប៉ះពាល់បន្សំ (Cumulative Impacts)។ ទោះបីស្ថានភាពធនធានអេកូឡូស៊ីក្នុងតំបន់គំរោងវិនិយោគនេះមិនទាន់ខូចខាតធ្ងន់ធ្ងរក្តី តែគ្មានឈើមានតម្លៃពាណិជ្ជកម្មសេសសល់ច្រើនទេ។ តែគំរោងអភិវឌ្ឍន៍ដាំដំណាំកៅស៊ូ របស់ក្រុមហ៊ុននឹងនាំមកនូវសក្តានុពលសេដ្ឋកិច្ចខ្ពស់ ដូច្នេះគំរោងនេះត្រូវបានចាត់ទុកថាជាប្រភេទគំរោងដែលមានហេតុប៉ះពាល់ពហុអវិជ្ជមានមធ្យម-Category B ។

**១៩៦.** ការពិគ្រោះយោបល់បានធ្វើឡើងជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរអង្គភាពពាក់ព័ន្ធ សរុបចំនួន០៩នាក់ (ឧបសម្ព័ន្ធ៧)។ ក្រុមការងារអង្កេតផ្នែកអេកូឡូស៊ី (១) ការអង្កេតអំពីសារព័ន្ធរុក្ខជាតិនៅក្នុងឡូត៍គំរូចំនួន ១៧ (២) ការអង្កេតអំពីសត្វព្រៃនៅតាមឡូត៍ និងការសំភាសន៍ និង (៣) ក្រុមការងារហោះឆ្លងកាត់គន្លងហោះហើរចំងាយ ២៥គ.ម និងធ្វើការអង្កេតលើផ្ទៃដីទំហំ ៨៦៥ ហិកតា ដូចបានកំណត់ត្រាដោយប្រព័ន្ធបង្ហាញទីតាំងសកល (**ឧបសម្ព័ន្ធ៤-៦**) ។

**១៩៧.** យោងទៅលើលទ្ធផលនៃការពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរ/ស្ថាប័ន ពាក់ព័ន្ធ ឃុំ ភូមិ និងប្រជាជនសហគមន៍ដែលពាក់ព័ន្ធ ការធ្វើអង្កេតអេកូឡូស៊ីជាក់ស្តែងលើទីវាលនិងការវាយតំលៃស្ថានភាពគំរប និងធនធានព្រៃឈើក្នុងស្ថានភាពបច្ចុប្បន្ន និងតាមរយៈការហោះអង្កេតពីលើ ក្រុមការងារយល់ឃើញថា គំរោងអភិវឌ្ឍន៍ដំណាំកៅស៊ូរបស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** អាចនឹងនាំមកនូវផលប៉ះពាល់បរិស្ថាន និងសង្គមមួយចំនួនដូចមានរៀបរាប់ខាងក្រោម:

Draft

## ៥-២ ហេតុប៉ះពាល់បរិស្ថាននិងសង្គម ក្នុងដំណាក់កាលមុនប្រតិបត្តិគំរោង

### ៥-២-១ ការប្រើប្រាស់ដី

១៩៨. ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** **(TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** បានទទួលការប្រទានសិទ្ធិពីរាជរដ្ឋាភិបាលជាមួយនឹង (១)- លិខិតលេខ ១៨៨៤ កសក. ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីករណីសំណើសុំសម្បទានដីចំនួន ១០.០០០ ហិកតា របស់ក្រុមហ៊ុន **TAN BIEN KAMPONG THOM APHIVATH CAUOTCHOUC CO., LTD.** សម្រាប់វិនិយោគ លើវិស័យដំណាំកៅស៊ូ និងបង្កើតរោងចក្រកែច្នៃ ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ សំរាប់វិនិយោគដំណាំកៅស៊ូ។ (២)- លិខិតជូនដំណឹងលេខ ៥០១ សជណ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០០៧ របស់ទីស្តីការ គណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំដីសម្បទានចំនួន ១០.០០០ ហិកតា របស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** **(TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** សម្រាប់វិនិយោគលើវិស័យកសិក-ឧស្សាហកម្ម ដាំកៅស៊ូ និងបង្កើតរោងចក្រ កែច្នៃ ស្ថិតនៅក្នុង ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ។ (៣)- លិខិតលេខ ២១០៧ កសក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីសំណើសុំសិទ្ធប្រទានពីរាជរដ្ឋាភិបាល ដើម្បីចុះហត្ថលេខាលើកិច្ចសន្យាដីសម្បទាន ចំនួន ៨.១០០ ហិកតា សម្រាប់វិនិយោគលើវិស័យកសិក-ឧស្សាកម្ម ដាំកៅស៊ូ និងបង្កើតរោងចក្រ កែច្នៃ ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ របស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** **(TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)**។ (៤) សិទ្ធិប្រទានលេខ ៣៨ សប្រទ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជាប្រទានសិទ្ធិជូនឯកឧត្តមបណ្ឌិត **ចន្ទ័ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះហត្ថលេខា លើកិច្ចសន្យាដីសម្បទានចំនួន ៨.១០០ ហិកតា ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ សម្រាប់វិនិយោគលើវិស័យ កសិ-ឧស្សាហកម្ម ដាំកៅស៊ូ និងបង្កើតរោងចក្រ កែច្នៃ ជាមួយក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** **(TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)**។ (៥)កិច្ចសន្យាចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពការវិនិយោគដាំដំណាំ កសិ-ឧស្សាហកម្ម ដាំកៅស៊ូ និងបង្កើតរោងចក្រកែច្នៃ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** **(TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** (ភ្ជាប់ជូន ក្នុងឧបសម្ពន្ធ ៣-១)។

**១៩៩.** រាជរដ្ឋាភិបាលបានធ្វើការប្រគល់ដីសរុបចំនួន **៨.១០០ ហិកតា** អោយទៅក្រុមហ៊ុនគ្រប់គ្រង និងប្រើប្រាស់ ក្នុងនោះមានៈ ដីសម្រាប់អភិវឌ្ឍន៍ចំការកៅស៊ូមានចំនួន ៧.៩៥០ ហិកតា និង ៥៥០ ហិកតា សមាប់រៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ដល់ដំណើរការផលិតកម្ម។ ក្រៅពីនោះក៏មានជាផ្ទៃព្រៃដែលត្រូវរក្សា (តំបន់ទ្រនាប់ដងអូរ) ចំនួន ៣.០៧១ ហិកតា ដីព្រៃបំរុងទុកសំរាប់ស្តាឡើងវិញ និងសិក្សាស្រាវជ្រាវ ចំនួន ១.១៩០ ហិកតា ហើយក៏មានសហគមន៍មូលដ្ឋានសុំបង្កើតសហគមន៍ព្រៃឈើ ភូមិថ្មសំលៀង ចំនួន ៩៣១ហិកតា។ ដូចមានបង្ហាញនៅក្នុងឧបសម្ពន្ធ ៣-១ ៈរបាយការណ៍ស្តីពីលទ្ធផលនៃការចុះសិក្សាទីតាំងស្នើសុំដីសម្បទានរបស់ក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ។

### ៥-២-២ ការរំខានដល់សិទ្ធិក្នុងការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋ

**២០០.** ទោះបីជាតំបន់នោះមានការកាត់ចេញនូវដីផ្ទះសម្បែង និងភូមិកររបស់ប្រជាជនមូលដ្ឋានក្តី ក៏ប៉ុន្តែមានប្រជាជនមួយចំនួនបានទៅរានដីតំបន់នោះដើម្បីធ្វើស្រែ-ចំការ។ វត្តមាននៃការរានដីដើម្បីធ្វើចំការនៅក្នុងតំបន់នោះ អាចធ្វើឱ្យប៉ះពាល់ដល់ភាគីទាំងសងខាង (គឺប្រជាជនមូលដ្ឋាន និងក្រុមហ៊ុន) តែគួរបញ្ជាក់ថា ការរានដីព្រៃ ដើម្បីធ្វើស្រែ-ចំការមិនមែនជាការស្របច្បាប់នោះទេ។ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋឃុំក្រយា នឹងមានការប៉ះពាល់ដីស្រែ-ចំការស្មាយចន្ទីរបស់ប្រជាពលរដ្ឋចំនួន១ភូមិ គឺភូមិអូរទឹកថ្លា មានប្រជាពលរដ្ឋប្រមាណ១០០គ្រួសារ ស្មើនឹង៥២៩ហិកតា។ ក៏ប៉ុន្តែក្រុមហ៊ុនមិនបានធ្វើការដោះស្រាយជាមួយប្រជាពលរដ្ឋនៅឡើយទេ ហើយប្រជាពលរដ្ឋក៏នៅតែបង្កបង្កើនផលនៅលើដីនោះនៅឡើយដែរ (តាមការរាយការណ៍ឱ្យដឹងពី **លោក ឌីន** ជាបុគ្គលិករបស់ក្រុមហ៊ុន តាន បៀន និង **លោក ឡៅ សារ៉ន** មេភូមិអូរទឹកថ្លា។)

***វិធានការកាត់បន្ថយ:*** *ផលប៉ះពាល់នេះអាចធ្វើការកាត់បន្ថយបានតាមរយៈការអនុវត្តន៍នូវវិធានការមួយចំនួនដូចខាងក្រោម:*

- *ក្រុមហ៊ុនត្រូវមានស្មារតីយោគយល់ដល់ប្រជាជនមូលដ្ឋាន ដែលគ្មានវិជ្ជាជីវៈមានជីវភាពទីទ័លក្រ តាមរយៈការផ្តល់នូវឱកាសការងារដល់ពួកគាត់ ដើម្បីរួមចំណែកលើកស្ទួយកំរស់ជីវភាពរបស់ពួកគាត់។*
- *ចំពោះដីចំការដែលផ្តល់ផលជារៀងរាល់ឆ្នាំ ត្រូវធ្វើការដោះដូរ (ប្រសិនបើចាំបាច់) ទៅតាមគោលការណ៍រួមមួយដែលភាគីទាំងសងខាងអាចទទួលយកបាន។*
- *ក្នុងករណីដែលពួកគាត់មិនព្រមធ្វើការដោះដូរ តែពួកគាត់ចង់កែប្រែដីចំការនោះទៅជាចំការកៅស៊ូ (ដើម្បីប្រមូលផលលក់អោយទៅក្រុមហ៊ុននៅពេលកៅស៊ូផ្តល់ផល) ក្រុមហ៊ុនត្រូវគាំទ្រដល់ពួកគាត់តាមរយៈការផ្តល់ពូជ និងការណែនាំផ្នែកបច្ចេកទេស។*

Draft

### ៥-២-៣ ហេតុប៉ះពាល់ទៅដល់ធនធានព្រៃឈើ

**២០១.** យោងតាមផែនទីប្រើប្រាស់ដី និងគំរបព្រៃឈើឆ្នាំ២០០៦ របស់រដ្ឋបាលព្រៃឈើបានបង្ហាញថា មានសហគមន៍សារព័ន្ធរុក្ខជាតិចំនួន០៣ប្រភេទគឺៈ (១) ព្រៃស្រោងមានចំនួន ៧.៩៥៥ហិកតា ស្មើនឹង៩៨.២១% (២) ព្រៃផ្សេងៗមានចំនួន ៣៨ហិកតា ស្មើនឹង ០.៤៧% នៃផ្ទៃដីសរុប និង (៣) ដីគ្មានគំរបព្រៃមានចំនួន ១០៧ហិកតា ស្មើនឹង ១.៣២% នៃផ្ទៃដីសរុប ។

**២០២.** យោងតាមការអង្កេតទៅលើសារព័ន្ធរុក្ខជាតិដែលមាននៅក្នុងព្រៃស្រោង បានបង្ហាញថាៈ ដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតធំជាង ៥០ស.ម មានជាមធ្យម ០១ដើមក្នុងមួយហិកតា ដូចនេះនៅក្នុងព្រៃស្រោង ចំនួន ៧.៩៥៥ហិកតា មានដើមឈើសរុប ៧.៩៥៥ដើម ។ ដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតធំជាង ៣០-៤៩ស.ម មានជាមធ្យម ១៣ដើមក្នុងមួយហិកតា ដូចនេះនៅក្នុងព្រៃស្រោង ចំនួន ៧.៩៥៥ហិកតា មានដើមឈើសរុប ១០៣.៤១៥ដើម ។ ដង់ស៊ីតេឈើ ដែលមានអង្កត់ផ្ចិតធំជាង ១០-២៩ស.ម មានជាមធ្យម ៧០ដើមក្នុងមួយហិកតា ដូចនេះនៅក្នុងព្រៃស្រោង ចំនួន ៧.៩៥៥ហិកតា មានដើមឈើសរុប ៥៥៦.៨៥០ដើម ។ ដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតធំជាង ៥-៩ស.ម មានជាមធ្យម ១២០ដើមក្នុងមួយហិកតា ដូចនេះនៅក្នុងព្រៃស្រោង ចំនួន ៧.៩៥៥ហិកតា មានដើមឈើសរុប ៩៥៤.៦០០ដើម ។ ដូចនេះ ស្ថានភាពគំរបព្រៃស្រោងក្នុងតំបន់គំរោងជាមធ្យមមាន ២៣ភាគរយ នៃផ្ទៃដីសរុបដែលបានសិក្សា ។

**២០៣.** ដូចនេះ គំរបព្រៃឈើដែលជាប្រភេទព្រៃស្រោង ចំនួន ៧.៩៥៥ ហិកតា ស្មើនឹង ៩៨.២១% នៃផ្ទៃដីសរុបនឹងត្រូវបាត់បង់ទាំងស្រុងដោយសារសកម្មភាពឈូសឆាយដីដើម្បីធ្វើការអភិវឌ្ឍន៍ដាំដំណាំកៅស៊ូ ។

***វិធានការកាត់បន្ថយៈ***

- *ក្រុមហ៊ុនត្រូវរៀបចំផែនការមូលនិធិបរិស្ថាន ដើម្បីរៀបចំផែនការដាំដើមឈើ នៅក្នុងតំបន់រក្សាទុក និងតំបន់ទ្រនាប់ ឡើងវិញ ។*

## ៥-៣ ហេតុប៉ះពាល់បរិស្ថាន និងសង្គម ក្នុងដំណាក់កាលប្រតិបត្តិគំរោង

### ៥-៣-១ ការប៉ះពាល់ដល់គុណភាពទឹក

**២០៤.** ការឈូសឆាយផ្ទៃដីទំហំ ៧.៩៥០ហិកតា ដើម្បីដាំកៅស៊ូនេះ បាននឹងធ្វើអោយប៉ះពាល់ដល់គុណភាពទឹកមួយចំនួនដូចខាងក្រោម :

១. នៅពេលឈូសឆាយព្រៃ សំណល់ដើមឈើជាច្រើន (ឫស គល់ ដើម មែក និងស្លឹក) ត្រូវបានបន្សល់ទុកដោយមិនបានសំអាត និងគរទុកនៅលើកំរាលព្រៃ ជាហេតុបណ្តាលឱ្យមានការខូចខាតទៅលើសារព័ន្ធរុក្ខជាតិដែលនៅសល់ ជាពិសេសរុក្ខជាតិដែលបានដុះនៅនឹងដីគំនរសំរាមទាំងនេះអាចនឹងធ្វើឱ្យកកស្ទះដល់ការហូររំដោះទឹកនៅក្នុងពេលដែលមានភ្លៀងធ្លាក់ខ្លាំង ។ ផលប៉ះពាល់នេះត្រូវបានចាត់**ទុកថា ជាផលប៉ះពាល់បណ្តោះអាសន្ន ។**

***វិធានការកាត់បន្ថយៈ*** *ការកកស្ទះនេះអាចធ្វើការទប់ស្កាត់បាន តាមរយៈការអនុវត្តន៍នូវវិធានការមួយចំនួនដូចខាងក្រោមៈ*

- *ត្រូវការពារតំបន់រក្សាទុក និងតំបន់ទ្រនាប់អូរ-ព្រែក ទៅតាមផែនការមេដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឯកភាព ដើម្បីការពារការហូរច្រោះដី ។*



Draft

២. ទឹកដែលហូរនៅផ្ទៃកខាងលើនៃខ្នងរបស់ផ្លូវនឹងកើតមានឡើងនៅក្នុងរដូវវស្សា បញ្ហាដែលកើតមាននៅក្នុងស្ថានភាពបែបនេះ គឺជាកំណរដីខ្សាច់នៅតាមប្រព័ន្ធស្ទឹងនានាដែលមានក្នុងតំបន់នោះ (ព្រែក និងអូរតូចៗ ដែលស្ថិតនៅក្នុងនិងក្រៅតំបន់ដីសម្បទាននេះ) ហើយហូរចាក់ទៅក្នុងទន្លេសាប។ កំលាំងទឹកហូរដែលកើតមានឡើងនៅក្នុងនិងក្រោយពេលភ្លៀងធ្លាក់ខ្លាំង តែងតែហូរនាំយកទៅនូវដីនិងសំណល់ឈើពីទីកន្លែងឈូសឆាយព្រៃ ធ្វើអោយដុះខ្សាច់នៅបាតនៃប្រព័ន្ធផ្លូវទឹកទាំងនោះ។ បង្កភាពក្រខ្វក់ដល់ទឹកដែលប្រជាជនមូលដ្ឋានប្រើសំរាប់ផឹក-និងការបោកគក់ និងជះឥទ្ធិពលអាក្រក់ទៅដល់ជីវិតនៅក្នុងទឹក និងមជ្ឈដ្ឋានរស់នៅ។ តែយោងតាមស្ថានភាពឋានលេខា និងទីតាំងភូមិសាស្ត្ររបស់ដីគំរោងវិនិយោគនេះ ការដុះខ្សាច់និងភាពល្អក់កករបង្កដោយការឈូសព្រៃ មិនបង្កអោយមានផលប៉ះពាល់អ្វីគួរអោយចាប់អារម្មណ៍នោះទេ។ នេះជា**ផលប៉ះពាល់បន្ទាប់បន្សំ**។

***វិធានការកាត់បន្ថយ:*** *ផលប៉ះពាល់នេះអាចធ្វើការទប់ស្កាត់បាន តាមរយៈការអនុវត្តន៍នូវវិធានការមួយចំនួនដូចខាងក្រោម:*

- *ត្រូវរៀបចំច្បារដំណាំ ឬសួនច្បារបន្ថែម ទៅតាមប្លង់ Landscape Architecture លើផ្ទៃដីទំនេរមិនប្រើប្រាស់ ដើម្បីកាត់បន្ថយការហូរច្រោះដោយ Surface Runoff នៅពេលមានភ្លៀងធ្លាក់ខ្លាំង។*
- *ស្តារគន្លងទឹកហូរដែលរាក់ ជាពិសេសនៅតាមមាត់លូឆងកាត់ផ្លូវ។*
- *រំដោះទឹកនៅតាមតំបន់ទំនាប មិនត្រឹមតែទៅផ្សើមផ្លូវដែលស្ទះគប៉ុណ្ណោះទេ តែថែមទាំងបានហូររំដោះទៅនូវទឹកភ្លៀងដែលជ្រាបមិនទាន់ និងទឹកដែលនៅសល់ពីការស្រូបយករបស់រុក្ខជាតិ កាត់បន្ថយនូវការកើតមាននូវទឹកជំនន់ភ្លាមៗ ពេលមានភ្លៀងធ្លាក់ខ្លាំងផងដែរ។ ម្យ៉ាងវិញទៀតការរំដោះទឹកនេះជាជំនួយដល់ការស្រូបយកនូវកករ បើមិនដូច្នោះទេវានឹងហូរធ្លាក់ចុះទៅផ្ទៃកខាងក្រោមរបស់ប្រព័ន្ធទឹកស្ទឹងជាមិនខាន។*
- *ត្រូវដាក់លូបន្ថែមនៅតាមតំបន់ទមនាបណាដែលធំ ដើម្បីជួយរំដោះទឹកពីម្ខាងផ្លូវ អោយបានទាន់ពេលវេលា។*

៣. <u>ក្រុមហ៊ុនបានប្រើជីធម្មជាតិទ្រាប់បាតចំនួន ០២តោន/ហិកតា និងជីគីមី NPK ចំនួន៥០០គ.ក្រ/ហិកតា ដើម្បីរក្សាសុខភាពនិងជម្រុញដល់ការលូតលាស់របស់កូនកៅស៊ូដែលទើបនឹងដាំថ្មីៗ។ ក្នុងរយៈពេល ០៥ឆ្នាំដំបូងនៃការដាំដុះ ក្រុមហ៊ុននឹងប្រើប្រាស់ជីសរីរាង្គ (Organic Fertilizer) ប្រភេទ (COMIX) ចំនួន១តោន/ហិកតា ដើម្បីជួយបំប៉នដល់ការលូតលាស់នៃកូនកៅស៊ូដែលបានដាំ។ ការប្រើប្រាស់ជីគីមីអាចនិងមានការប៉ះពាល់ដល់គុណភាពដី និងគុណភាពទឹក ក៏ប៉ុន្តែហេតុប៉ះពាល់នេះមានកំរិតតិចតួច</u>

និងមានរយៈពេលមួយមានកំណត់ ពីព្រោះក្រុមហ៊ុនភាគច្រើនប្រើប្រាស់ជីសរីរាង្គជំនួសឱ្យមានការប្រើប្រាស់ ជីគីមី ។

***វិធានការកាត់បន្ថយ:*** *ហេតុប៉ះពាល់នេះអាចធ្វើការកាត់បន្ថយបានតាមរយៈការអនុវត្តន៍នូវវិធានការមួយចំនួនដូចជា:*

- *ត្រូវប្រើប្រាស់ជីគីមី ឬ ថ្នាំសំលាប់សត្វល្អិត (ក្នុងករណីដែលមាន) ដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។*
- *ហាមប្រើដាច់ខាតចំពោះជីគីមី ឬ ថ្នាំសំលាប់សត្វល្អិត ដែលរាជរដ្ឋាភិបាលកម្ពុជាបានហាមឃាត់ ។*
- *ត្រូវកាត់បន្ថយការប្រើប្រាស់ជីសរីរាង្គដែលធានាគុណភាពជំនួសឱ្យការប្រើប្រាស់ជីគីមី ឬថ្នាំសំលាប់សត្វល្អិត ។*

### ៥-៣-២ ការហូរច្រោះដី

**២០៥.** ក្រុមហ៊ុនបានឈូសព្រៃរៀបចំដីដាំដំណាំកៅស៊ូឡើងវិញចំនួន ៦.៩៧០ ហិកតា បានបង្ករអោយប៉ះពាល់ដល់ការហូរច្រោះ តែផលប៉ះពាល់នេះមានកំរិតតិចតួចហើយមានលក្ខណៈជា **ផលប៉ះពាល់បណ្តោះអាសន្ន (រយៈពេលខ្លី)** ។ ព្រោះក្រុមហ៊ុនបាន *រក្សាទុកផ្ទៃដីព្រៃតំបន់ទ្រនាប់អូរ-ព្រែក ទៅតាមផែនការបែងចែកការប្រើប្រាស់ដីទៅតាមផែនការមេដែលបានឯកភាពដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយ ។ ផ្ទៃដីព្រៃដែលរក្សាទុកដើម្បីការពារការហូរច្រោះនេះមានទំហំ៣.០៧១ហិកតា ។ម្យ៉ាងវិញទៀត ក្រុមហ៊ុនបានដាំដំណាំរួមផ្សំ (Intercrops) ឬរុក្ខជាតិគំរប (Cover Plants) នៅតាមចន្លោះជួរកៅស៊ូ ក្នុងរយៈពេល៣ឆ្នាំដំបូងរហូតដល់ពេលកៅស៊ូទាំងនោះមានចុងមែកដុះស្ទើរជិត ។ ធ្វើដូច្នេះ មានផលប្រយោជន៍ច្រើនពីព្រោះការធ្វើដំណាំរួមផ្សំនេះអាច (១) អាចទប់ស្កាត់កំរិតនៃការហូរច្រោះបានច្រើន និង (២) អាចកាត់បន្ថយតំលៃនៃការគ្រប់គ្រងបានមួយចំណែក ទំរាំដល់ពេលដែល កៅស៊ូផ្តល់ផល ។*

### ៥-៣-៣ សម្លេង

**២០៦.** គ្មានផលប៉ះពាល់ដែលបង្កឡើងដោយសម្លេង នៅក្នុងតំបន់នេះទេ ព្រោះសកម្មភាពឈូសឆាយព្រៃត្រូវបានបញ្ចប់ទាំងស្រុងហើយ ។

### ៥-៣-៤ ការហៀរប្រេងឥន្ធនៈ ប្រេងរំអិល និងប្រេងខ្មៅចេញពីកន្លែងស្តុកប្រេង និងរោងម៉ាស៊ីនភ្លើង

**២០៧.** ផលប៉ះពាល់ដែលបង្កឡើងដោយ ការហៀរប្រេងឥន្ធនៈ ប្រេងរំអិល និងប្រេងខ្មៅចេញពីកន្លែងស្តុកប្រេង និងរោងម៉ាស៊ីនភ្លើង មានតិចតួចណាស់ស្ទើរ តែមិនអាចគណនាបាន ។ ព្រោះ ជាក់ស្តែងទីតាំងស្នាក់របស់

ក្រុមហ៊ុននេះ ស្ថិតនៅលើទីទួលមិនលិចទឹក, បរិមាណប្រេងឥន្ធនៈដែលប្រើប្រាស់មានចំនួនតិចតួច។ ក្រុមការងារ មិនបានសង្កេតឃើញមានស្នាមចាក់ប្រេងខ្មៅនៅជុំវិញទីតាំងរោងម៉ាស៊ីនទេ។

### ៥-៣-៥ ការបំភាយឧស្ម័នកាបូនិក និងសារធាតុបំពុលផ្សេងៗទៀតទៅក្នុងបរិយាកាស

**២០៨.** ផលប៉ះពាល់នេះមានទំហំតូចស្ទើរតែមិនអាចគណនាបាន។ ផលប៉ះពាល់ប្រភេទនេះជាផល ប៉ះពាល់បន្ទាប់បន្សំ។

### ៥-៣-៦ ការចោលសំណល់រឹងផ្សេងៗទៅក្នុងមជ្ឈដ្ឋានជុំវិញ

**២០៩.** កំណើនសំណល់រឹងដែលមិនអាចរលាយបានមានដូចជា : សំបកអាគុយ ធុងប្រេង សំបកប្លាស្ទិក កំប៉ុងដប គ្រឿងបន្លាស់ម៉ាស៊ីនដែលលែងប្រើការកើត និងសំភារៈផ្សេងៗទៀត ដែលមិនអាចបំបែកបានតាមលក្ខណៈជីវសាស្ត្រនឹងកើតមានឡើងដោយចៀសពុំរួចទេ។ **ផលប៉ះពាល់បន្ទាប់បន្សំ តែមានលក្ខណៈជាផលប៉ះពាល់រយៈពេលវែង**។

***វិធានការណ៍កាត់បន្ថយ*** *: ដើម្បីកាត់បន្ថយនូវហេតុប៉ះពាល់ ដែលបង្កឡើងដោយសារការចោលសំណល់រឹងពីបុគ្គលិក-កម្មករក្រុមហ៊ុនត្រូវ :*

- *ចោលសំណល់រឹងទៅក្នុងរណ្តៅជាមួយនឹងការលុបដីជាប្រចាំ។*
- *ប្រសិនបើអាច ចាំបាច់ត្រូវចោលសំរាមនៅក្រៅកន្លែងរស់នៅ តែប្រសិនបើមិនអាចត្រូវជ្រើសរើសកន្លែងណាមួយដោយមានការរៀបចំឱ្យមានសណ្តាប់ធ្នាប់ ចៀសវាងការបង្កអោយក្រខ្វក់ដល់ប្រភពទឹកឬអណ្តូងទឹកដែលធ្វើឱ្យបាត់បង់សោភ័ណភាព និងមានក្លិនស្អុយ។*

### ៥-៣-៧ ការបាត់បង់ទីជម្រក និងហេតុប៉ះពាល់លើសត្វព្រៃ

**២១០.** ការឈូសព្រៃដើម្បីដាំកៅស៊ូទំហំ ៦.៩៧០ហិកតា បានធ្វើអោយបាត់បង់ទីជម្រក និងបាត់បង់ ឈើចំនួន ៦០ប្រភេទ ជុល្លិព្រឹក្ស៤៤ប្រភេទ និងតិណជាតិចំនួន៥៥ប្រភេទ ប្រៀបធៀបជាមួយនឹងប្រភេទឈើ នៅទូទាំងប្រទេសមាន ២.៣០៨ប្រភេទ និង ៨.០០០ប្រភេទ នៅក្នុង ឥណ្ឌូចិន។ **ផលប៉ះពាល់ប្រភេទនេះគឺជាផលប៉ះពាល់រយៈពេលវែង**។

<u>* សំគាល់:</u> *ទោះបីជាស្ថានភាពគំរបព្រៃក្នុងតំបន់នេះ (ទាំងព្រៃស្រោង ឬព្រៃពាក់កណ្តាលស្រោង) នៅល្អបង្គួរក្តី តែមិនមានឈើដែលមានអង្កត់ផ្ចិតសមស្របសម្រាប់ធ្វើពាណិជ្ជកម្មច្រើនទេ។ ក្នុងតំបន់នេះ ឈើភាគច្រើនស្ថិតក្នុងអំបូរ Dipterocarpaceae ចំពោះឈើបេង (Caesalpiniaceae) នាងនួន (Papilionaceae) ធ្នង់ (Papilionaceae) នៅមានសេសសល់មួយៗ តែពុំមានអង្កត់ផ្ចិតធំទេ (ប្រភេទនេះមានកំណត់នៅក្នុងតារាងក្រហម IUCN)។ ចំណែកឈើជិតផុតពូជដូចជា ប្រាំគំឡឹង (Combretaceae) គ្រើល (Anacardiaceae)*

*ឈើខ្មៅ (Ebenaceae) អង្កត់ខ្មៅ (Ebenaceae) ត្រយឹង (Ebenaceae) តាត្រាវ (Loganiaceae) ក្រញូង (Papilionaceae) បែហសាន (Caesalpiniaceae) អង្កាញ់ (Caesalpiniaceae) មិនមានជួបប្រទះនៅក្នុងតំបន់នេះទេ ។*

**២១១.** ហេតុប៉ះពាល់ចំពោះសត្វព្រៃបង្កឡើងដោយការឈូសសំអាតព្រៃ ដើម្បីដាំដំណាំកៅស៊ូមិនធ្ងន់ធ្ងរប៉ុន្មានទេ ពីព្រោះថាសត្វព្រៃទាំងអស់នោះអាចធ្វើបំលាស់ទីពីតំបន់មួយទៅតំបន់មួយទៀត តាមតំបន់ និងច្រករបៀងបានយ៉ាងងាយស្រួល ។ ផលប៉ះពាល់ប្រភេទនេះអាចចាត់ទុកថា **ជាផលប៉ះពាល់បន្ទាប់បន្សំ តែជាផលប៉ះពាល់មានរយៈពេលវែង (ឧបសម្ព័ន្ធ៥ៈ ផែនទីបង្ហាញពីតំបន់របៀងសត្វព្រៃ)** ។

***វិធានការកាត់បន្ថយៈ*** *ផលប៉ះពាល់នេះអាចធ្វើការកាត់បន្ថយបានតាមរយៈការអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោមៈ*

- *ត្រូវបិទផ្លាក និងហាមឃាត់ ចំពោះការចូលរបស់បុគ្គលទាំងឡាយណាដែលមិនបានទទួលការផ្តល់សិទ្ធិចូលទៅក្នុងតំបន់សម្បទាន ដើម្បីការពារជីវិតសត្វព្រៃពីការប្រមាញ់ ។ វិធីសាស្ត្រនេះក៏មានសារៈសំខាន់ដើម្បីការពារឧប្បត្តិហេតុនៃការប្រមាញ់រវាងកម្មករក្រុមហ៊ុន និងអ្នកប្រមាញ់ពីខាងក្រៅដែរ ។*

- *ត្រូវអប់រំបុគ្គលិកកម្មកររបស់ក្រុមហ៊ុន ដើម្បីការពារនូវការប្រមូលអនុផលព្រៃឈើទាំងឡាយណា (ទាំងធនធានលើដី និងក្នុងទឹក) នៅក្នុងរូបភាពនៃការលក់ដូរ ។*

* <u>សំគាល់</u> : យោងតាមលទ្ធផលនៃការធ្វើអង្កេតទៅលើសត្វព្រៃបង្ហាញថា មានសុកុណជាតិចំនួន ៣២ប្រភេទ បានជួបប្រទះនៅក្នុងតំបន់នៅក្នុងរយៈពេលនៃការសិក្សា ប្រៀបជាមួយនឹងសុកុណជាតិ៥០ប្រភេទ (តាមរយៈការសម្ភាសន៍ជាមួយប្រជាជនរស់នៅក្នុងតំបន់) និង ៦៣០ប្រភេទ ដែលបានកត់ត្រាទុកនៅទូទាំងប្រទេស ។ ចំណែកឯពពួកថនិកសត្វមានចំនួន០៥ប្រភេទ ដែលបានជួបប្រទះនៅក្នុងរយៈពេលនៃការសិក្សា បើប្រៀបជាមួយនឹងថនិកសត្វ ១៥ប្រភេទ (តាមរយៈការសម្ភាសន៍ជាមួយនឹងប្រជាជនរស់នៅក្នុងតំបន់) និង ២១៨ ប្រភេទ ដែលបានកត់ត្រាទុកនៅទូទាំងប្រទេស **(ដូចមានបង្ហាញជូននៅក្នុងតារាង : ៤-១០ និង៤-១១ ក្នុងកថាខ័ណ្ឌ ១២០ និង១២២)** ។

### ៥-៣-៨ ការប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋដែលរស់នៅផ្នែកខាងក្រោម

**២១២.** ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋនៅខ្សែទឹកខាងក្រោម គឺការទាញយកទឹកពីអូរដងត្រក និងអូរកោសលង់ ឬអូរពរលង់ ដើម្បីយកទឹកមកស្រោចស្រពលើផលដំណាំ ជាពិសេសដំណាំស្រូវ ដែលបានដាំក្បែរប្រភពទឹកខាងលើ ។ ការរៀបចំផែនការស្ទាក់ទឹករបស់ក្រុមហ៊ុន ដើម្បីយកមកប្រើប្រាស់ក្នុងការស្រោចស្រពទៅលើការបណ្តុះកូនកៅស៊ូ និងសកម្មភាពប្រើប្រាស់ផ្សេងៗនៅក្នុងទីស្នាក់ការ ឬការដ្ឋានក្រុមហ៊ុន



Draft

អាចបង្កឱ្យមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋដែលរស់នៅខ្សែទឹកខាងក្រោម គឺអំឡុងពេលរដូវប្រាំង (ពាក់កណ្តាលខែវិច្ឆិកា-ចុងពាក់កណ្តាលខែឧសភា) ដែលតំបន់នេះមិនសូវសំបូរប្រភពទឹក។

***វិធានការកាត់បន្ថយ :***

- *ត្រូវសហការជាមួយក្រុមជំនាញនៃក្រសួងធនធានទឹក និងឧតុនិយម ឬមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ ដើម្បីរៀបចំផែនការ និងរចនាគំរោងឱ្យបានត្រឹមត្រូវ មុននឹងធ្វើសាងសង់ប្រព័ន្ធស្តាក់ទឹកជៀសវាងបង្កឱ្យមានការប៉ះពាល់ដល់សិទ្ធិនៃការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋដែលរស់នៅខ្សែទឹកខាងក្រោម។*
- *ត្រូវធ្វើការផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរងការប៉ះពាល់ពីការសាងសង់ប្រព័ន្ធស្តាក់ទឹក។*

### ៥-៣-៩ ការប៉ះពាល់ដល់មុខរបររបស់ប្រជាពលរដ្ឋ

**២១៣.** ប្រជាពលរដ្ឋរបស់ឃុំក្រយា ជាពិសេសភូមិចំនួន ០១ គឺភូមិអូរទឹកថ្លា ដែលមាន ការពាក់ព័ន្ធជា មួយនឹងគំរោងវិនិយោគរបស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** បានប្រកបមុខរបរធ្វើស្រែ-ចំការជាចំបងនៅក្នុង និងក្បែរទីតាំងគំរោងស្នើសុំ។ ក្រៅពីការប្រកបមុខរបរធ្វើស្រែ-ចំការ ប្រជាពលរដ្ឋបានប្រកបការងាររកផល-អនុផលព្រៃឈើ កាប់ឈើ-អុស ការដាក់អន្ទាក់សត្វ និងធ្វើការនេសាទ ជាលក្ខណៈគ្រួសារនៅតាមដងអូរ ដែលជាមុខរបរបន្ទាប់បន្សំ ក្រោយពីប្រមូលផលស្រូវរួច។ ដូចនេះ សកម្មភាពនៃការអភិវឌ្ឍន៍ ដាំដំណាំកសិ-ឧស្សាហកម្ម (ដាំដំណាំកៅស៊ូ) នឹងធ្វើឱ្យបាត់បង់នូវប្រាក់ ចំណូលមួយផ្នែកចេញពីការរកផល-អនុផលព្រៃឈើ ការកាប់ឈើធ្វើអុស ការចាប់សត្វ ការនេសាទជាដើម។

***វិធានការកាត់បន្ថយ :***

- *ត្រូវផ្តល់អត្ថិភាពការងាររបស់ក្រុមហ៊ុន ទៅដល់ប្រជាពលរដ្ឋដែលរងការបាត់បង់នូវមុខរបរបន្ទាប់បន្សំពីសកម្មភាពអភិវឌ្ឍន៍ដាំដំណាំកៅស៊ូ។*
- *ត្រូវរៀបចំមូលនិធិសង្គម ដើម្បីជួយដល់ប្រជាពលរដ្ឋដែលរងការប៉ះពាល់ពីសកម្មភាពគំរោង រួមមានការបណ្តុះបណ្តាលក្នុងការដាំដុះកៅស៊ូ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ព្រមទាំងផ្តល់ពូជដល់ពួកគាត់ ដើម្បីប្រកបមុខរបរខាងលើនេះ ក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ។*

Draft

## ៥-៣-១០ ហេតុប៉ះពាល់លើសុខភាពការងារ និងផែនការសុវត្ថិភាព

### ៥-៣-១០-១ ការការពារជំងឺគ្រុនចាញ់

**២១៤.** ពាក់ព័ន្ធទៅនឹងសកម្មភាពនៃការអភិវឌ្ឍន៍ដាំកៅស៊ូ និងការកែច្នៃផលិតផល ក្រុមហ៊ុនត្រូវការកំលាំងពលកម្មប្រមាណ ៩៨៤ នាក់ សំរាប់ឆ្នាំទី១ និងកើនរហូតដល់ ១.០១១ នាក់ សំរាប់ឆ្នាំទី៥ (មានបង្ហាញជូននៅក្នុងកថាខណ្ឌ ទី៩៣ ទំព័រ ៥៤)។ ហេតុប៉ះពាល់ដល់សុខភាពរបស់បុគ្គលិក-កម្មករនឹងអាចកើតមានឡើងនូវជំងឺគ្រុនចាញ់ ដោយសារក្រុមហ៊ុនពុំបានផ្តល់នូវជំរកស្នាក់នៅឱ្យបានសមរម្យ។

**វិធានការការពារ :** ក្រុមហ៊ុនត្រូវសហការជាមួយការិយាល័យសុខាភិបាលមូលដ្ឋាន និងមជ្ឈមណ្ឌលជាតិការពារជំងឺគ្រុនចាញ់ ដើម្បីអនុវត្តនូវកម្មវិធីការពារជំងឺគ្រុនចាញ់។ កម្មវិធីទាំងនេះមាន : (១) ការស្វែងរកឱ្យបានទាន់ពេលវេលាតាមរយៈការពិនិត្យលើលក្ខណៈគ្លីនីក ចំពោះអ្នកផ្ទុកជំងឺដែលមានលក្ខណៈខ្ពស់ (២) ផ្តល់ការព្យាបាលអោយបានត្រឹមត្រូវ និងគ្រប់គ្រាន់នៅគ្រប់ករណីនៃការកើតមានទាំងអស់ (៣) ធ្វើរបាយការណ៍អំពីករណីនៃការកើតមាន និងតាមដានអ្នកដែលប៉ះពាល់ឬនៅជាមួយនឹងអ្នកជំងឺ (៤) ផ្តល់ការណែនាំអំពីការ ប្រើប្រាស់ថ្នាំការពារជំងឺគ្រុនចាញ់អោយបានត្រឹមត្រូវ (៥) ជ្រលក់មុងជាមួយនឹងរបាយ Pyrathroid (៦) អនុវត្តគំរោងកែលំអអនាម័យ ដើម្បីលុបបំបាត់កន្លែងរស់នៅរបស់មូស និងផ្តល់ការអប់រំអំពីបញ្ហាសុខភាពនិងការការពារជំងឺគ្រុនចាញ់ (៧) ដាក់សំណាញ់តាមទ្វារ និងបង្អួចផ្ទះ (៨) ប្រើប្រាស់មុងជាប្រចាំ (៩) ស្លៀកពាក់ខោអាវដៃវែង និងប្រើសារធាតុការពារមូស (១០) តាមដានគ្លីនីក និងរោគសញ្ញារបស់អ្នកជំងឺគ្រុនចាញ់ (១១) ធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលអោយបានទាន់វេលា និង (១២) ត្រួតពិនិត្យនូវឧប្បទ្ទវហេតុ និងកំណត់អំពីទីតាំងនៃការកើតមានជំងឺគ្រុនចាញ់។

### ៥-៣-១០-២ ការការពារជំងឺគ្រុនឈាម

**២១៥.** ប្រសិនបើគ្មានការគ្រប់គ្រងកន្លែងដែលមូសរស់នៅឱ្យបានជិតដល់ទេ អាចនឹងធ្វើឱ្យកើតជំងឺគ្រុនឈាមបាន អនុសាសន៍សំខាន់ៗសំរាប់ការការពារ និងការកាត់បន្ថយនូវការកើតឡើងរបស់ជំងឺមានដូចជា: (១) សំអាតកន្លែងដែលមូសរស់នៅ (ទាំងក្នុងលក្ខខ័ណ្ឌធម្មជាតិ និងសិប្បនិម្មិត) ជាកន្លែងដែលមានទឹកបង្កលក្ខណៈសមស្របដល់ការបង្កាត់ពូជមូសដែលមាននៅជុំវិញនោះ (២)អប់រំកម្មករ និងសហគមន៍មូលដ្ឋានឱ្យបំផ្លាញទីកន្លែងជំរករបស់មូស (៣)ធ្វើការអង្កេត និងកំណត់អំពីដង់ស៊ីតេរបស់មូសដែលចំលងមេរោគ និង (៤)បាញ់ថ្នាំសំលាប់មូសជាប្រចាំ ជាពិសេសនៅពេលដែលមានមូសច្រើន។

### ៥-៣-១០-៣ វិធានការណ៍ការគ្រប់គ្រងការរាតត្បាត



Draft

១៨៥. វិធានការណ៍សំខាន់ៗសម្រាប់គ្រប់គ្រងការរាគត្បាតរបស់ជំងឺឆ្លងមានដូចជា: (១) ត្រូវបំបែកអ្នកជំងឺ ឱ្យនៅកន្លែងផ្សេង និងផ្តល់ការព្យាបាលជាពិសេសទៅតាមយថាប្រភេទនៃជំងឺ (២) បាញ់ថ្នាំក្នុងបរិវេណរស់នៅចំងាយ២០០ម៉ែត្រ ដើម្បីសំលាប់មូសដែលពេញវ័យ (៣) ស្វែងរក និងបំផ្លាញទីតាំងជំរកមូស (៤) ចាំបាច់ត្រូវប្រើប្រាស់ថ្នាំសំលាប់ពងមូស ចំពោះទីកន្លែងដែលមានមូសច្រើន និង (៥) អប់រំដល់បុគ្គលិកកម្មករ និងសហគមន៍អំពីវិធានការណ៍គ្រប់គ្រងការរាគត្បាត ។

## ៥-៣-១០-៤ ការការពារជំងឺដែលបង្កឡើងដោយការប្រើប្រាស់ទឹកមិនស្អាត

២១៦. ការកើតជំងឺគ្រុនពោះវៀន រាគមួល អាសន្នរោគ រលាកថ្លើម និងទឹកស៊ីជើងមានកំរិតខ្ពស់ ដោយសារការខ្វះអនាម័យ ការប្រើប្រាស់បង្គន់សាធារណៈមានកំរិតទាប ការផ្គត់ផ្គង់ទឹកស្អាតនៅមានកំរិត និងការខ្វះអនាម័យរបស់កម្មករ។

**វិធានការការពារ** : អនុសាសន៍មួយចំនួនដែលអនុវត្តសម្រាប់ការពារនូវការកើតនូវជំងឺខាងលើមានៈ (១) ក្រុមហ៊ុនត្រូវផ្តល់ទឹកស្អាតដល់កម្មករ (២) ត្រួតពិនិត្យជាប្រចាំអំពីគុណភាពរបស់ទឹក (វត្តមានរបស់បាក់តេរី សារធាតុគីមី និងពណ៌របស់ទឹក) (៣) ត្រូវធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា (៤) តាមដានរកប្រភពចំលង និងផ្តល់ការព្យាបាល (៥) ធានាបាននូវសុវត្ថិភាព និង អនាម័យការបោះចោលនូវសំណល់រឹងនៅក្នុងផ្ទះដែលសង់សំរាប់កម្មករ (៦) កែលំអការសម្អាតបរិស្ថាន ឱ្យសហគមន៍មូលដ្ឋាន ដោយការសង់បង្គន់អនាម័យ និងកន្លែងសំរាប់ចោលសំណល់រឹង (៧) កែលំអអនាម័យបុគ្គលជាពិសេសចំពោះអ្នករៀបចំអាហារ (៨) ផ្តល់វ៉ាក់សាំងចំពោះបុគ្គលិក ឬកម្មករបរទេសដែលពុំមានអង់ទិករប្រឆាំងជំងឺគ្រុនពោះវៀន អាសន្នរោគ និងរលាកថ្លើម និង (៩) រាយការណ៍និងធ្វើការត្រួតពិនិត្យអំពីឧប្បត្តិហេតុរបស់ជំងឺ។ ការណែនាំរបស់អង្គការសុខភាពពិភពលោកស្តីពីបទដ្ឋានគុណភាពទឹកសំរាប់ការប្រើប្រាស់ផ្សេងៗមានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ៤-៥ (តារាង៣) ។

## ៥-៣-១០-៥ ការការពារជំងឺផ្លូវភេទ

២១៧. បន្តការពារជំងឺផ្លូវភេទចំពោះកម្មករ និងសហគមន៍មូលដ្ឋានអាចធ្វើបានតាមរយៈ (១) អប់រំបុគ្គលិកកម្មករអំពីគ្រោះថ្នាក់នៃការឆ្លងជំងឺអេដស៍ និងជំងឺផ្លូវភេទផ្សេងៗទៀតដូចជាការទប់ស្កាត់នូវទំនាក់ទំនងជាមួយអ្នកដែលធ្វើអាជីវកម្មលើផ្លូវភេទ ការប្រើប្រាស់ស្រោមអនាម័យ ណែនាំអ្នកជំងឺឱ្យព្យាបាលជាមួយនឹងគ្រូពេទ្យដែលមានបទពិសោធន៍ និងមិនត្រូវព្យាបាលដោយខ្លួនឯង និង (២) រាយការណ៍អំពីអ្នកជំងឺស្វែងរកអ្នកចំលង និងត្រួតពិនិត្យករណីនៃការកើតមានរបស់ជំងឺ ដោយការិយាល័យសុខាភិបាលនៅក្នុងតំបន់។ ប្រសិទ្ធិភាពនៃកម្មវិធីការពារជំងឺផ្លូវភេទ ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារសុខាភិបាល សហគមន៍មូលដ្ឋាន និងក្រុមហ៊ុន។

Draft

## ៥-៣-១០-៦ ការរៀបចំផ្ទះ និងសុខភាព

**២១៨.** ការរៀបចំផ្ទះមិនបានត្រឹមត្រូវ (ខ្វះអនាម័យ មនុស្សច្រើនហួសកំរិត និងអាកាសអាប់អួរ ចំពោះការហូបចុករបស់កម្មករត្រូវផ្តល់ឱ្យបានគ្រប់គ្រាន់) អាចនាំឱ្យមានការចំលងប៉ារ៉ាស៊ីត ជំងឺចំលងតាមខ្យល់ គ្រោះថ្នាក់ដោយការប៉ះទង្គិច និងស្រេួសជាដើម។ តែបញ្ហាទាំងនេះអាចកាត់បន្ថយតាមរយៈការអនុវត្តន៍នូវ **វិធានការណ៍ការពារ** : (១) ក្រុមហ៊ុនបានរៀបចំប្លង់កសាងទីស្នាក់ស្នួលបានត្រឹមត្រូវ (២) បានផ្តល់ផ្ទះដល់កម្មករទៅតាមលក្ខខ័ណ្ឌ: (ក) លក្ខណៈរូបៈ ទីតាំងផ្ទះចាំបាច់ត្រូវស្ថិតនៅផុតពីកំពស់ទឹកជំនន់ស្ថិតនៅឆ្ងាយពីទីកន្លែងដែលអាចផ្តល់ភាពក្រខ្វក់ និងកន្លែងដែលមានសត្វល្អិតច្រើន។ (ខ) លក្ខណៈអនាម័យៈ បានផ្តល់ទឹកស្អាតឱ្យបានគ្រប់គ្រាន់ ជាមួយនឹងមធ្យោបាយសំរាប់ដុសលាងនិងងូតទឹក មានបង្គន់អនាម័យ និងកន្លែងសំរាប់ចោលសំណល់រឹងត្រឹមត្រូវ និង (៣) មានតារាងបាល់បោះ និងបាល់ទះ) និងមណ្ឌលសុខភាព។

## ៥-៣-១០-៧ កំនើននៃគ្រោះថ្នាក់ក្នុងពេលធ្វើការ និងការធ្វើចរាចរ

**២១៩.** ដើម្បីទប់ស្កាត់នូវគ្រោះថ្នាក់ក្នុងពេលធ្វើការ និងការធ្វើចរាចរក្រុមហ៊ុនត្រូវ: (១) រៀបចំនិងអនុវត្តនូវគោលការណ៍សុវត្ថិភាព និងសុខភាព (២) ផ្តល់មធ្យោបាយសង្គ្រោះបន្ទាន់នៅគ្រប់កន្លែងធ្វើការទាំងអស់ (៣) ផ្តល់មធ្យោបាយសំរាប់ព្យាបាលបន្ទាន់នៅក្នុងគ្លីនិករបស់ទីស្នាក់ការស្នួល (៤) រៀបចំវិធានការណ៍សំរាប់សង្គ្រោះបន្ទាន់ ដើម្បីបញ្ជូនអ្នករងគ្រោះ ឬអ្នកជំងឺធ្ងន់ធ្ងរទៅកាន់មន្ទីរពេទ្យ (៥) អនុវត្តន៍ច្បាប់នៃការបើកបរ និងការណែនាំលើផ្លូវដឹកជញ្ជូន និង(៦) អប់រំសហគមន៍អំពីសុវត្ថិភាពនៃការប្រើប្រាស់ផ្លូវដែលនៅក្នុងតំបន់។

## ៥-៤ ហេតុប៉ះពាល់សេដ្ឋកិច្ច

**២២០.** យោងតាមរបាយការណ៍វិភាគសេដ្ឋកិច្ចអាជីវកម្មកៅស៊ូ របស់ក្រុមហ៊ុនបានបង្ហាញអំពីលំហូរសាច់ប្រាក់សុទ្ធ (Net Cash Flow) ដែលនឹងចាប់ផ្តើមប្រត្តិបត្តិការនៅឆ្នាំ ២០០៨ រហូតដល់ឆ្នាំ ២០២៧ រយៈពេល ២០ឆ្នាំ ក្នុងការអនុវត្តន៍គំរោងការដាំដុះ និងអាជីវកម្មដំណាំកៅស៊ូ គឺបង្ហាញថាៈ លំហូរសាច់ប្រាក់មានការប្រែប្រួល ពីមួយឆ្នាំទៅមួយឆ្នាំ អាស្រ័យទៅលើការបណ្តាក់ទុន និងចំណូលចំណាយលើកិច្ចប្រត្តិបត្តិការហិរញ្ញវត្ថុនៃឆ្នាំនីមួយៗ។ ប្រភពទិន្នន័យសំរាប់ការធ្វើវិភាគប្រសិទ្ធភាពសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ក្នុងផែនការមេនេះ គឺផ្អែកទៅលើលំហូរសាច់ប្រាក់សុទ្ធ។

**២២១.** ម៉្យាងវិញទៀត អនុលោមតាមទ្រឹស្តីវិនិយោគទុន អត្រាការប្រាក់ ឬអត្រាអប្បហារ ត្រូវបានយកមកគណនាក្នុងការរកប្រសិទ្ធិភាពហិរញ្ញវត្ថុ នៃគំរោងការធ្វើវិនិយោគ។ បច្ចុប្បន្នអត្រាការប្រាក់នៅតាមបណ្តាធនាគារពាណិជ្ជកម្មនានា មានការខុសគ្នាបន្តិចបន្តួច បំរែបំរួលពី ៣% ទៅ៦% ក្នុងមួយឆ្នាំ ក្នុងប្រភេទគណនីមានកាលកំណត់។

Draft

**២២២.** ក្រុមហ៊ុនបានធ្វើការវិភាគភាពរឹងប៉ឹងនៃគំរោងវិនិយោគតាមរយៈការគណនាតំលៃបច្ចុប្បន្ន (Present Value) នៃលំហូរសាច់ប្រាក់រយៈពេល២០ឆ្នាំ ដោយកំណត់យកអត្រា Discounted Rate ស្មើនឹង ១០% ការគណនាតំលៃបច្ចុប្បន្នសុទ្ធ (Net Present Value - NPV) និងការគណនា (Internal Rate of Return - IRR)។ លទ្ធផលនៃការគណនាបានបង្ហាញថាៈ (១) តម្លៃបច្ចុប្បន្ន (Present Value) = ២៩.២៥៩.៦៣៨ ដុល្លាអាមេរិក ក្រុមហ៊ុនត្រូវការដើមទុនអាជីវកម្មសំរាប់ ១០ ឆ្នាំដំបូង គឺប្រមាណជាង ២៩.២ លានដុល្លាអាមេរិក ប្រសិនបើអត្រា Discount Rate=៨%។ (២) តម្លៃបច្ចុប្បន្នសុទ្ធ (Net Present Value or NPV) = ៥.៤៧៤.៦១៣ ដុល្លាអាមេរិកៈ តម្លៃបច្ចុប្បន្នសុទ្ធនៃគំរោងវិនិយោគនេះ ជាចំនួនវិជ្ជមាន ដែលក្រុមហ៊ុនអាចសន្និដ្ឋានបានថា ការ ធ្វើអាជីវកម្មមានដំណើរការល្អ និងទទួលយកបាន។ (៣) ការគណនា Intenal Rate of Return (IRR) = ១២% : តួលេខនេះគឺធ្វើឱ្យក្រុមហ៊ុនអាចមាន ក្តីសង្ឃឹមច្រើន ក្នុងការធ្វើអាជីវកម្មរបស់ខ្លួន ព្រោះ Discounted Rate កំណត់ត្រឹម ៨%តូចជាង Intenal Rate of Return (IRR) អាចមានរហូតដល់ ១២ ភាគរយ។ (៤) រយៈពេលប្រមូលទុនមកវិញ (Payback Period): ក្នុងរង្វង់រយៈពេល១៧ឆ្នាំ ក្រុមហ៊ុនអាចមានលទ្ធភាពទូទាត់សង និងប្រមូលបានមកវិញ នូវដើមទុនវិនិយោគនៃគំរោងអាជីវកម្មនេះ។ (៥) សន្ទស្សន៍ផលចំណេញ (Profitability Index or Benefit/Cost Ratio) ក្នុងរយៈពេល ២០ ដំបូងនេះ ត្រូវបានគណនាឃើញប្រហែល ១.១៤។ គំរោងវិនិយោគនេះអាចទទួលយកបាន ព្រោះសន្ទស្សន៍ផលចំណេញធំជាង០១ ឬអាចនិយាយបានថា ១ដុល្លាអាមេរិក ដែលបានវិនិយោគ នឹងអាចបង្កើនតម្លៃបាន ១,១៤ ដុល្លាអាមេរិក។

## ៥-៥ ហេតុប៉ះពាល់ក្នុងតំបន់

**២២៣.** គំរោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មនេះ បង្កឱ្យមានហេតុប៉ះពាល់អវិជ្ជមានក្នុងតំបន់គ្មានអ្វីគួរអោយចាប់អារម្មណ៍នោះទេ។ ហេតុប៉ះពាល់ក្នុងតំបន់ដែលអាចកើតមាននៅក្នុងរយៈពេលនៃការអភិវឌ្ឍន៍មានដូចជា :

(១) ការប្រើប្រាស់ដីចំនួន ៧.៥៥០ ហិកតា សម្រាប់អភិវឌ្ឍន៍គំរោងដំណាំកសិ-ឧស្សាហកម្មនេះ នឹងមិនធ្វើឱ្យមានហេតុប៉ះពាល់ក្នុងតំបន់ទេ ពីព្រោះតំបន់នេះគឺជាដីព្រៃដែលទទួលរងការធ្វើអាជីវកម្មបែបអនាធិបតេយ្យគ្មានឈើដែលមានតំលៃពាណិជ្ជកម្មច្រើនទៀតឡើយ។ ផ្ទុយទៅវិញក្រោយពេលធ្វើការអភិវឌ្ឍន៍ ចប់តាមទិសដៅផលិតកម្មហើយគំរោងនេះ នឹងនាំមកនូវផលប្រយោជន៍វិជ្ជមានច្រើនយ៉ាងទាំងនៅក្នុងវិស័យបរិស្ថាន និងសេដ្ឋកិច្ចសង្គម។

(២) សកម្មភាពអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្មនៅក្នុងតំបន់នេះ នឹងបង្កអោយមានការប៉ះពាល់ដល់ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ដែលពឹងអាស្រ័យទៅលើធនធានធម្មជាតិ ដូចជា ការរកអនុផលព្រៃឈើ។ ដូចនេះ ដើម្បីកាត់បន្ថយការប៉ះពាល់ដែលកើតមានឡើងពីសកម្មភាពគំរោង ក្រុមហ៊ុននឹងធ្វើការ

ជ្រើសរើសប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់នោះមកបំរើការងារនៅក្នុងការដ្ឋានអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មនេះ ព្រមទាំងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋអាចរកអនុផលព្រៃឈើនៅក្នុងតំបន់ណាដែលក្រុមហ៊ុនមិនបានធ្វើអាជីវកម្ម ។

## ៥-៦ ហេតុប៉ះពាល់បន្ទាប់បន្សំ

**២២៤.** ហេតុប៉ះពាល់បន្សំ ដែលអាចកើតមានដោយសារគំរោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មនៅក្នុងតំបន់គឺការផ្លាស់ប្តូរនូវលំនាំនៃការប្រើដី ដែលកើតមានឡើងដោយការរីករាលដាលរបស់គំរោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មនៅក្នុងតំបន់ជុំវិញនោះ ។ ការផ្លាស់ប្តូរនូវលំនាំនៃការប្រើប្រាស់នេះ ធ្វើឱ្យមានការប្រែក្លាយដីព្រៃធម្មជាតិ អោយទៅជាចំការដំណាំឧស្សាហកម្ម ។ ហេតុប៉ះពាល់បន្សំរបស់គំរោងមានលក្ខណៈជាហេតុប៉ះពាល់វិជ្ជមាន ពីព្រោះថាព្រៃនៅក្នុងតំបន់នោះមិនមានតំលៃពាណិជ្ជកម្មខ្ពស់ ។ ហើយម៉្យាងវិញទៀតនិន្នាការនៃការប្រមូលផលនិងអនុផលព្រៃឈើក្នុងតំបន់សម្បទាន នៅក្រោមសម្ពាធនៃភាពក្រីក្ររបស់សហគមន៍បាននឹងកំពុងតែធ្វើអោយធនធានដ៏ផុយស្រួយនេះរេចរឹលទៅៗ រីឯជីវភាពរស់នៅរបស់សហគមន៍ខ្លួនក៏កាន់តែក្រីក្រទៅៗផងដែរ ។

## ៥-៧ ហានិភ័យពីគ្រោះធម្មជាតិ

**២២៥.** នៅពេលដែលក្រុមហ៊ុនធ្វើការឈូសឆាយដាំដុះដំណាំកៅស៊ូ ដែលមិនបានអនុវត្តទៅតាមផែនការមេសំរាប់គំរោងអភិវឌ្ឍន៍ដាំដំណាំកៅស៊ូរបស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** ក្នុងករណីហានិភ័យអាចកើតមានឡើងដោយសារខ្យល់ព្យុះធម្មជាតិ ការហូរច្រោះដីជាដើម ដែលបង្កឱ្យមានមហន្តរាយដល់ផលដំណាំដែលកើតមានឡើងដោយសារគ្រោះធម្មជាតិ ។

***វិធានការកាត់បន្ថយ :***

- *នៅក្នុងដំណាក់កាលឈូសឆាយដីព្រៃសំរាប់ដាំដុះដំណាំកៅស៊ូ ត្រូវរក្សាទុកព្រៃធម្មជាតិកំរាស់យ៉ាងតិច ១០០-២០០ម៉ែត្រ ព័ទ្ធជុំវិញអនុតំបន់គំរោងនីមួយៗ ដើម្បីការពារហានិភ័យដែលអាចកើតមានឡើងលើផលដំណាំកៅស៊ូ ។*
- *ក្នុងករណីគ្មានរបាំងព្រៃធម្មជាតិ ត្រូវដាំដើមឈើឡើងវិញ ដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់រាល់គ្រោះធម្មជាតិដែលអាចកើតមានឡើង ។*

## ៥-៨ ភាពចាំបាច់នៃការវាយតម្លៃហេតុប៉ះពាល់បន្ថែម

**២២៦.** គំរោងអភិវឌ្ឍន៍កៅស៊ូរបស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONGTHOM APHIVATH CAOUTCHOUC CO., LTD.)** មានទីតាំងស្ថិត នៅក្នុង

តំបន់ដីសម្បទានសេដ្ឋកិច្ច ដូច្នេះក្រោយពីបានការ អនុម័តអោយមានការអភិវឌ្ឍន៍ហើយ ក្រុមហ៊ុនត្រូវសហការណ៍ ជាមួយក្រុមជំនាញ ដើម្បីធ្វើការវាយតម្លៃ ហេតុប៉ះពាល់អោយបានពេញលេញ។ ការវាយតំលៃហេតុប៉ះពាល់ បន្ថែមត្រូវយកចិត្តទុកដាក់ទៅលើបញ្ហាមួយ ចំនួនដូចជា:

ក- បន្តកំណត់អត្តសញ្ញាណ និងទំហំផ្ទៃដីរបស់ប្រជាពលរដ្ឋមូលដ្ឋាន ដែលនៅសេសសល់ អោយបានត្រឹមត្រូវ ទៅតាមគោលការណ៍គតិយុត្ត ដែលក្រុមហ៊ុនធ្លាប់បានអនុវត្តនីកន្លងមក។

ខ- ក្រុមហ៊ុនត្រូវដាក់របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម សម្រាប់គំរោងសាងសង់រោងចក្រកែច្នៃកៅស៊ូក្រែប និងរងចាំការអនុញ្ញាតិជាមុនសិន ទើបដំណើរការបាន។

Draft